# ព្រះរាជក្រម

នស/រកម/០៦០៧/០១៦

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងធនធានទឹក និង ឧតុនិយម
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា និង រដ្ឋមន្ត្រីក្រសួងធនធានទឹក និង ឧតុនិយម

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីការគ្រប់គ្រងធនធានទឹកនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០៧ នាសម័យប្រជុំរដ្ឋសភាលើកទី៦ នីតិកាលទី៣ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០០៧ នាសម័យប្រជុំពេញអង្គព្រឹទ្ធសភាលើកទី៣ នីតិកាលទី២ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ :

# ច្បាប់

# ស្តីពី

# ការគ្រប់គ្រងធនធានទឹកនៅក្នុង ព្រះរាជាណាចក្រកម្ពុជា

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

# ជំពូកទី ១

# បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

ច្បាប់នេះ មានគោលដៅធានាឱ្យមានការគ្រប់គ្រងធនធានទឹកប្រកបដោយប្រសិទ្ធភាព និងនិរន្តរភាពនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដើម្បីសម្រេចបាននូវការងារអភិវឌ្ឍសេដ្ឋកិច្ច សង្គម និងសុខមាលភាពរបស់ប្រជាពលរដ្ឋ ។

ច្បាប់នេះកំណត់ :

-សិទ្ធិ និងកាតព្វកិច្ចនៃអ្នកប្រើប្រាស់ទឹក

-គោលការណ៍គ្រឹះសំខាន់ៗ សម្រាប់ការគ្រប់គ្រងធនធានទឹក

-ការចូលរួមរបស់សហគមន៍អ្នកប្រើប្រាស់ទឹក ក្នុងការអភិវឌ្ឍន៍ធនធានទឹក ប្រកបដោយនិរន្តរភាព ។

**មាត្រា ២.-**

ក្នុងច្បាប់នេះ ពាក្យបច្ចេកទេសមួយចំនួនមានន័យថា :

-ទឹក គឺទឹកលើដី ទឹកក្រោមដី និងទឹកក្នុងអាកាស ។

-ធនធានទឹក គឺសមុទ្រ ទន្លេ ស្ទឹង ព្រែក ជ្រោះ ជ្រលងជងអូរ បឹងបួ ត្រពាំង ថ្លុក អាងទឹក ។

-ទឹកក្រោមដី គឺទឹកដែលហូរនៅក្រោមដីក្នុងចន្លោះថ្មតូច ធំ និងភាគល្អិតនៃដីដែលផ្លាស់ទីពីកន្លែងមួយទៅកន្លែងមួយទៀត ។

-ល្អាងទឹកក្រោមដី គឺទឹកក្រោមដីដែលស្ថិតនៅជាអចិន្ត្រៃយ៍ក្នុងល្អាងធម្មជាតិក្រោមដី ។

-អាងទន្លេ គឺតំបន់ភូមិសាស្ត្រដែលកំណត់ដោយព្រំប្រទល់ទីជម្រាលនៃប្រព័ន្ធទឹកហូរដោយរាប់បញ្ចូលទាំងទឹកលើដី និងទឹកក្រោមដី ។

-អាងទន្លេរង គឺផ្នែកមួយនៃអាងទន្លេ ។

-ទន្លេអន្តរជាតិ គឺទន្លេដែលមានភូមិសាស្ត្រពាក់ព័ន្ធដល់ទឹកដីប្រទេសចាប់ពី

-ច្រាំងទន្លេ ស្ទឹង ព្រែក អូរ ប្រឡាយ បឹងបួ និងអាងទឹក គឺចំណែកដីដែលធម្មតាលិចដោយទឹកនៅក្នុងទន្លេ ស្ទឹង ព្រែក អូរ ប្រឡាយ បឹងបួ និងអាងទឹក ដោយរាប់បញ្ចូលទាំងដី ថ្ម ឬ អង្គធាតុដទៃទៀតដែលជាប់នៅនឹងច្រាំងនោះ ដោយមិនរាប់បញ្ចូលនូវដី ថ្ម ឬ អង្គធាតុដទៃទៀតដែលនៅឆ្ងាយពីច្រាំង និងលិចទឹកម្តងម្កាលនោះទេ ។

-ឆ្នេរ សមុទ្រ ទន្លេ ស្ទឹងគឺចំណែកដី ឬ ខ្សាច់ដែលមានសណ្ឋានជម្រាល និងលិចទឹកម្តងម្កាល ។

-បាតទន្លេ ស្ទឹង ព្រែក អូរ ប្រឡាយ បឹងបួ និងអាងទឹក គឺផ្នែកមួយនៃដីដែលកំណត់ដោយច្រាំងទន្លេ ស្ទឹង ព្រែក អូរ ប្រឡាយ បឹងបួ និងអាងទឹកដែលគ្របដណ្តប់ដោយទឹក ។

-តម្រូវការសាធារណៈ គឺការផ្គត់ផ្គង់ទឹកទៅតាមទីក្រុង និងជនបទ ការផលិតស្បៀង ការផលិតថាមពលវារីអគ្គិសនី ការបំរើវិស័យកសិកម្ម វិស័យឧស្សាហកម្ម វិស័យនាវាចរ និងការរក្សាឱ្យមានធារទឹកអប្បបរមា ដើម្បីថែរក្សាបរិស្ថាន ជីវិតមនុស្ស ជីវិតមច្ឆាជាតិ និងរុក្ខជាតិនានា ។

-ការងារទឹក គឺសំណង់ទំនប់ធំ តូច ទំនប់បង្វៀរ ទំនប់បញ្ឈប់ទឹក ទំនប់ការពារទឹកជំនន់ ប្រឡាយដោះទឹកធំតូច ប្រព័ន្ធស្រោចស្រព អាងទឹកធំ តូច ប្រឡាយនាំទឹក អណ្តូងទឹកគ្រប់ប្រភេទ ទំនប់វារីអគ្គិសនី និងសំណង់ដទៃទៀត ដែលបានសាងសង់ក្នុងគោលបំណងបង្វែរទឹក រក្សាទឹកទុក នាំទឹកយកទឹកប្រើប្រាស់ អភិរក្ស ការពារធនធានទឹក ដោះទឹកចេញពីតំបន់ដីលិចទឹក ការពារកាត់បន្ថយនូវឥទ្ធិពលទឹកជំនន់ និងសង្គ្រោះបន្ទាន់ផ្សេងៗទៀតដែលពាក់ព័ន្ធនឹងទឹក ។

-អាជ្ញាប័ណ្ណទឹក គឺប័ណ្ណដែលផ្តល់សិទ្ធិប្រើប្រាស់ទឹក និងធនធានទឹកឱ្យដល់បុគ្គលគ្រប់រូបដើម្បីធ្វើអាជីវកម្ម និងអភិវឌ្ឍ ។

-បុគ្គល គឺរូបវន្តបុគ្គល ឬ នីតិបុគ្គលទោះក្នុងន័យជាឯកជន ឬ សាធារណៈក៏ដោយ ។

មាត្រា ៤.-

ទឹក និងធនធានទឹក ជាសម្បត្តិរបស់រដ្ឋ ។

**មាត្រា ៤.-**

ទឹក និងធនធានទឹកត្រូវបានគ្រប់គ្រង និងអភិវឌ្ឍដោយផ្អែកទៅលើវិធីសាស្ត្រគ្រប់គ្រងធនធានទឹកចំរុះ ។

វិធីសាស្ត្រគ្រប់គ្រងធនធានទឹកចំរុះនេះ នឹងពិចារណាទៅលើ :

-គ្រប់ទិដ្ឋភាពទាំងអស់នៃធនធានទឹក

-ទំនាក់ទំនងរវាងធនធានទឹក និងទិដ្ឋភាពដទៃទៀតនៃបរិស្ថានធម្មជាតិ

-តម្រូវការប្រើប្រាស់ទឹកសំរាប់មនុស្ស បរិស្ថាន និងវិស័យផ្សេងទៀត ដើម្បីឱ្យមាននិរន្តរភាព និងប្រសិទ្ធភាព ។

ការអនុវត្តនីវិធីសាស្ត្រគ្រប់គ្រងធនធានទឹកចំរុះ ត្រូវធ្វើក្នុងពេលតែមួយ និងក្នុងក្របខ័ណ្ឌសហប្រតិបត្តិការរវាងរាល់ស្ថាប័នពាក់ព័ន្ធ ។

**មាត្រា ៥.-**

ក្រសួងធនធានទឹក និងឧតុនិយមមានភារកិច្ចគ្រប់គ្រង ដឹកនាំ និងត្រួតពិនិត្យ ក្នុងការអនុវត្តនីច្បាប់នេះ ។ ក្រសួងធនធានទឹក និងឧតុនិយមត្រូវពិគ្រោះយោបល់ជាមួយនឹងក្រសួងពាក់ព័ន្ធនានា ។ ក្នុងករណីចាំបាច់ រាជរដ្ឋាភិបាលអាចនឹងបង្កើតគណៈកម្មការចំរុះចំពោះមុខដើម្បីដោះស្រាយ និងសំរបសំរួលការងាររវាងបណ្តាក្រសួងពាក់ពន្ធ័ ។

**មាត្រា ៦.-**

ក្នុងការអនុវត្តនីច្បាប់គ្រប់គ្រងធនធានទឹក ក្រសួងធនធានទឹក និងឧតុនិយម ត្រូវកំណត់គោលនយោបាយគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍធនធានទឹក ស្របតាមតម្រូវការរបស់តំបន់នីមួយៗនៅទូទាំងព្រះរាជាណាចក្រកម្ពុជា ក្នុងទិសដៅធានានិរន្តរភាពធនធានទឹក និងប្រសិទ្ធ-ភាពក្នុងការប្រើប្រាស់ទឹក ដើម្បីជៀសវាងមហន្តរាយ និងវិវាទផ្សេងៗ ។

ការបែងចែកតំបន់គ្រប់គ្រង អភិរក្ស និងអភិវឌ្ឍធនធានទឹកត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ៧.-**

ការសហការ និងការចូលរួមរបស់ស្ថាប័នពាក់ព័ន្ធ ផ្នែកឯកជន អ្នកទទួលផលគ្រប់ប្រភេទ អង្គការក្រៅរដ្ឋាភិបាល និងអង្គការអន្តរជាតិ នឹងត្រូវបានជំរុញដោយរាជរដ្ឋាភិបាល

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

នៅក្នុងសកម្មភាពដែលទាក់ទងទៅនឹងការគ្រប់គ្រង ការវិនិយោគ ការធ្វើអាជីវកម្ម ការអភិរក្ស និងការអភិវឌ្ឍន៍ធនធានទឹក ។

## ជំពូកទី ២
## សារពើភ័ណ្ឌ និងផែនការគ្រប់គ្រងធនធានទឹក

**មាត្រា ៨.-**

ក្រសួងធនធានទឹក និងឧតុនិយម មានភារកិច្ចរៀបចំ និងរក្សាទុកនូវរាល់សារពើភ័ណ្ឌធនធានទឹកនៃព្រះរាជាណាចក្រកម្ពុជា ។ សារពើភ័ណ្ឌនេះ បង្ហាញអំពីទីតាំង បរិមាណ និងគុណភាពនៃធនធានទាំងនោះ ក្នុងរយៈពេលពេញមួយឆ្នាំទៅមួយឆ្នាំ ។

ទិន្នន័យស្តីពីបរិមាណ និងគុណភាពទឹក និងព័ត៌មានផ្សេងៗពាក់ព័ន្ធនឹងទឹកដែលស្ថាប័ននានាប្រមូលបានត្រូវបញ្ជូនមកក្រសួងធនធានទឹក និងឧតុនិយមតាមស្តង់ដារបច្ចេកទេស ។

ព័ត៌មាន និងទិន្នន័យខាងលើនេះអាចផ្តល់ជូនបានដោយឥតគិតថ្លៃដល់គ្រប់ស្ថាប័នរាជរដ្ឋាភិបាល និងសហគមន៍នានា ក្នុងទិសដៅបំរើផលប្រយោជន៍សាធារណៈ លើកលែងតែព័ត៌មាន និងទិន្នន័យសម្ងាត់ ។

ក្រសួងធនធានទឹក និងឧតុនិយម អាចតម្រូវឱ្យមានការបង់ប្រាក់ចំពោះពាក្យសុំទាំងឡាយណា ដែលធ្វើឡើងក្នុងគោលបំណងអាជីវកម្ម ។

**មាត្រា ៩.-**

ក្រសួងធនធានទឹក និងឧតុនិយម មានភារកិច្ចរៀបចំផែនការធនធានទឹកជាតិ ។

រាល់គម្រោងការងារទឹក ត្រូវរៀបចំឡើងដោយផ្អែកលើទិន្នន័យ និងព័ត៌មានក្នុងបញ្ជីសារពើភ័ណ្ឌធនធានទឹក ស្របតាមផែនការធនធានទឹកជាតិ ផែនការអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ ផែនការបរិស្ថានជាតិ និងបរិស្ថានតំបន់ ដើម្បីរក្សាឱ្យបាននូវតុល្យភាពទៅតាមតម្រូវការទឹកនាពេលបច្ចុប្បន្ន និងពេលអនាគត ។

**មាត្រា ១០.-**

ក្រសួងធនធានទឹក និងឧតុនិយម មានភារកិច្ចទទួលខុសត្រូវក្នុងការគ្រប់គ្រងអាងទន្លេ អាងទន្លេរង ទឹកលើទីជំរាល ទឹកក្រោមដី និងល្អាងទឹកក្រោមដីដោយសហការជាមួយនឹងក្រសួងពាក់ព័ន្ធ ។

នីតិវិធីនៃការរៀបចំ និងការអនុវត្តន៍ផែនការនៃការគ្រប់គ្រង ការអភិរក្ស និងការអភិវឌ្ឍន៍អាងទន្លេ អាងទន្លេរង ទឹកលើទីជំរាល ទឹកក្រោមដី និងល្អាងទឹកក្រោមដី ត្រូវកំណត់ដោយអនុក្រឹត្យ ។

## ជំពូកទី ៣
## ការអភិវឌ្ឍន៍ និងការប្រើប្រាស់ធនធានទឹក

**មាត្រា ១១.-**

បុគ្គលគ្រប់រូប មានសិទ្ធិប្រើប្រាស់ធនធានទឹកក្នុងបរិមាណមួយមិនលើសពីសេចក្តីត្រូវការចាំបាច់ជាមូលដ្ឋានសម្រាប់ការហូបចុក បោកគក់ ងូត និងតម្រូវការផ្សេងទៀត រួមមានការចិញ្ចឹមសត្វ ការចិញ្ចឹមត្រី ការស្រោចស្រពសួនច្បារ និងដំណាំ ដោយចៀសវាងមិនឱ្យមានការប៉ះពាល់ដល់សិទ្ធិស្របច្បាប់របស់អ្នកដទៃ ។

តម្រូវការខាងលើនេះ មិនតម្រូវឱ្យសុំអាជ្ញាប័ណ្ណទឹកឡើយ ។

**មាត្រា ១២.-**

ការបង្វែរទឹក ការយកទឹក ការប្រើប្រាស់ធនធានទឹក ក្នុងគោលបំណងកសិកម្ម ឬឧស្សាហកម្ម លើសពីកំរិតដែលមានចែងក្នុងមាត្រា ១១ និងសំណង់ការងារទឹកដែលពាក់ពន្ធ័ តម្រូវឱ្យមានការសុំអាជ្ញាប័ណ្ណទឹក ឬ លិខិតអនុញ្ញាត ។

បែបបទនៃការសុំនេះ នឹងមានចែងនៅក្នុងអនុក្រឹត្យ ។

ការយកខ្សាច់ ដី ថ្ម ក្រួស ប្រេងកាត និងឧស្ម័នពីបាត ច្រាំង ឆ្នេរសមុទ្រ ឆ្នេរទន្លេ ស្ទឹង ព្រែក អូរ បឹងបួ តម្រូវឱ្យមានការសុំអាជ្ញាប័ណ្ណទឹក ។ បែបបទបច្ចេកទេសជលសាស្ត្រដែលពាក់ព័ន្ធនឹងការងារនេះនឹងមានចែងលំអិតនៅក្នុងអនុក្រឹត្យ ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

ការលុបទន្លេ ស្ទឹង ព្រែក អូរ បឹងបួ ប្រឡាយ អាងទឹក និងអាងធម្មជាតិ តម្រូវឱ្យមានការសុំអាជ្ញាប័ណ្ណទឹក ឬ លិខិតអនុញ្ញាត ។ បែបបទនៃការសុំនេះ នឹងមានចែងនៅក្នុងអនុក្រឹត្យ ។

ការសាងសង់ស្ពានតូច ធំកាត់ទន្លេ ស្ទឹង កំពង់ផែ ឬ សំណង់អាគារតូច ធំលើច្រាំង និងឆ្នេរ តម្រូវឱ្យមានការឯកភាពផ្នែកបច្ចេកទេសជលសាស្ត្រជាមុន ពីក្រសួងធនធានទឹក និងឧតុនិយម ។

ការបង្វែរទឹកពីប្រភពដើមចេញពីទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវមានការអនុញ្ញាតនិងយល់ព្រមពីរាជរដ្ឋាភិបាលកម្ពុជា ដោយមានការអនុម័តយល់ព្រមពីស្ថាប័ននីតិប្បញ្ញត្តិ ។

**មាត្រា ១៣.–**

លក្ខខណ្ឌ ទម្រង់បែបបទ និងនីតិវិធីនៃការផ្តល់ ការផ្ទេរ ការព្យួរទុក ការកំណត់រយៈពេល ការពន្យារពេល ការលុបចោលអាជ្ញាប័ណ្ណទឹក ត្រូវកំណត់ដោយអនុក្រឹត្យ ។

ការកំរិតតម្លៃនៃការប្រើប្រាស់ទឹកដែលជាកម្មវត្ថុនៃអាជ្ញាប័ណ្ណទឹក នឹងមានកំណត់នៅក្នុងអនុក្រឹត្យ ។

**មាត្រា ១៤.–**

មុនពេលផ្តល់អាជ្ញាប័ណ្ណទឹកដល់បុគ្គលណាមួយ ក្រសួងធនធានទឹក និងឧតុនិយមត្រូវពិគ្រោះយោបល់ជាមួយស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរមូលដ្ឋានលើការប្រើប្រាស់ទឹក និងការសាងសង់សំណង់ការងារទឹកដែលបុគ្គលនោះស្នើឡើង ។

**មាត្រា ១៥.–**

អ្នកកាន់អាជ្ញាប័ណ្ណទឹក មានសិទ្ធិផ្ទេរទាំងស្រុង ឬ ចំណែកខ្លះទៅឱ្យអ្នកដទៃផ្សេងទៀតបាន ក្រោយពីមានការយល់ព្រមពីក្រសួងធនធានទឹក និងឧតុនិយម ។

**មាត្រា ១៦.–**

រាជរដ្ឋាភិបាល អាចធ្វើការកែប្រែអាជ្ញាប័ណ្ណទឹក ក្នុងករណីមានតម្រូវការចាំបាច់ ដើម្បីបម្រើផលប្រយោជន៍សាធារណៈ ។ ក្នុងករណីនេះ អ្នកកាន់អាជ្ញាប័ណ្ណទឹកអាចបានទទួលនូវសំណងសមស្រប ។

**មាត្រា ១៧.-**

ក្រសួងធនធានទឹក និងឧតុនិយម អាចធ្វើការកែប្រែ ឬ លុបចោលអាជ្ញាប័ណ្ណទឹកបាន តាមសំណូមពររបស់អ្នកកាន់អាជ្ញាប័ណ្ណទឹក ។

ក្រសួងធនធានទឹក និងឧតុនិយម អាចកែប្រែ ព្យួរទុក ឬ លុបចោលបាននូវអាជ្ញាប័ណ្ណទឹក ក្នុងករណីដែលអ្នកកាន់អាជ្ញាប័ណ្ណទឹកបាន :

-រំលោភលើលក្ខខណ្ឌដែលមានចែងក្នុងអាជ្ញាប័ណ្ណទឹក

-រំលោភលើបទប្បញ្ញត្តិនៃច្បាប់ និងលិខិតបទដ្ឋានផ្សេងៗដែលពាក់ព័ន្ធនឹងច្បាប់នេះ

-ប្រើប្រាស់បរិមាណទឹកលើសពីការអនុញ្ញាត

-ទុកចោលមិនបានអនុវត្តការងារក្នុងរយៈពេលពីរឆ្នាំ បន្ទាប់ពីថ្ងៃទទួលអាជ្ញា-ប័ណ្ណទឹក

-ផ្ទេរអាជ្ញាប័ណ្ណទឹកដោយគ្មានការយល់ព្រមពីក្រសួង

-ធ្វើឱ្យប៉ះពាល់ដល់សុខភាពសាធារណៈ ឬ បរិស្ថាន

-បដិសេធមិនព្រមបង់តម្លៃទឹក ដោយគ្មានមូលហេតុត្រឹមត្រូវ ។

ក្នុងករណីខាងលើ អ្នកកាន់អាជ្ញាប័ណ្ណទឹកត្រូវធ្វើសេចក្តីបញ្ជាក់ជាលាយល័ក្ខណ៍អក្សរមកក្រសួងធនធានទឹក និងឧតុនិយម ដើម្បីបំភ្លឺអំពីមូលហេតុនៃការប្រព្រឹត្តរបស់ខ្លួន ។ រាល់កំហុសឆ្គង អាចតម្រូវឱ្យអ្នកកាន់អាជ្ញាប័ណ្ណទឹកធ្វើការទូទាត់ជាសំណងក្នុងរយៈពេលមួយកំណត់ ។

**មាត្រា ១៨.-**

លើរាល់ការសម្រេចរបស់មន្ត្រីមានសមត្ថកិច្ចនៃក្រសួងធនធានទឹក និងឧតុនិយម អ្នកកាន់អាជ្ញាប័ណ្ណទឹកមានសិទ្ធិតវ៉ាទៅប្រធានស្ថាប័នក្នុងរយៈពេល៣០ថ្ងៃ គិតពីថ្ងៃដែលចេញសេចក្តីសម្រេចខាងលើនេះ ។ ពាក្យតវ៉ាត្រូវបញ្ជាក់ឱ្យបានច្បាស់ពីមូលហេតុ ។

ក្នុងករណីមិនសុខចិត្តនឹងសេចក្តីសម្រេចរបស់ក្រសួង អ្នកកាន់អាជ្ញាប័ណ្ណទឹកអាចធ្វើបណ្តឹងទៅតុលាការតាមច្បាប់ ។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

6/18

## ជំពូកទី ៤
## សហគមន៍កសិករប្រើប្រាស់ទឹក

**មាត្រា ១៩.-**

ដើម្បីធានាបាននូវការគ្រប់គ្រង និងការប្រើប្រាស់ប្រព័ន្ធធារាសាស្ត្រប្រកបដោយប្រសិទ្ធភាព និងនិរន្តរភាព ក្រសួងធនធានទឹក និងឧតុនិយមត្រូវទទួលខុសត្រូវលើការរៀបចំបង្កើតសហគមន៍កសិករប្រើប្រាស់ទឹក ។

កសិករដែលប្រើប្រាស់ទឹកក្នុងប្រព័ន្ធធារាសាស្ត្រជាមួយគ្នា ឬ ផ្នែកណាមួយនៃប្រព័ន្ធនេះ មានសិទ្ធិបង្កើតជាសហគមន៍កសិករប្រើប្រាស់ទឹក ។

លក្ខន្តិកៈនៃសហគមន៍កសិករប្រើប្រាស់ទឹកត្រូវចុះក្នុងបញ្ជីសហគមន៍កសិករប្រើប្រាស់ទឹកនៅមន្ទីរធនធានទឹក និងឧតុនិយមខេត្ត ក្រុង ។ បន្ទាប់ពីការចុះបញ្ជីនេះ សហគមន៍កសិករប្រើប្រាស់ទឹក មានសិទ្ធិគ្រប់គ្រាន់ក្នុងការអនុវត្តនូវលក្ខន្តិកៈរបស់ខ្លួននិងត្រូវបានទទួលស្គាល់ជាផ្លូវការ ។

នីតិវិធីនៃការបង្កើត ការរំលាយចោល តួនាទី និងភារកិច្ចនៃសហគមន៍កសិករប្រើប្រាស់ទឹក ត្រូវកំណត់ដោយអនុក្រឹត្យ ។

## ជំពូកទី ៥
## ទឹកក្រោមដី

**មាត្រា ២០.-**

បុគ្គលដែលជីក ឬ ខួងអណ្តូងទឹកក្នុងគោលបំណងធ្វើជាមុខរបរ ឬ អាជីវកម្ម ត្រូវផ្តល់របាយការណ៍លំអិតស្តីពីដំណើរការ លក្ខណៈបច្ចេកទេស និងព័ត៌មានផ្សេងៗទៀតនៃការជីក ឬ ខួងអណ្តូងទឹករបស់ខ្លួនមកក្រសួងធនធានទឹក និងឧតុនិយម ។

ការប្រើប្រាស់ទឹកក្រោមដី និងល្បាងទឹកក្រោមដីក្នុងគោលបំណងធ្វើជាមុខរបរ ឬ ធ្វើអាជីវកម្មដែលលើសពីកំរិតដែលមានចែងក្នុងមាត្រា ១១ តម្រូវឱ្យមានការសុំអាជ្ញាប័ណ្ណទឹក ។

ការកំណត់តំបន់ហាមឃាត់ នឹងមានចែងក្នុងអនុក្រឹត្យ ។

**មាត្រា ២១.–**

បុគ្គលទាំងឡាយ ដែលបានជួបប្រទះប្រភពទឹកក្រោមដី ល្អាងទឹកក្រោមដី ក្នុងពេលបំពេញការងាររុករករ៉ែ និងសកម្មភាពផ្សេងៗទៀត ត្រូវផ្តល់ព័ត៌មានមកក្រសួងធនធានទឹក និងឧតុនិយម ។

## ជំពូកទី ៦
## ការការពារគុណភាពទឹក

**មាត្រា ២២.–**

រាល់ការបញ្ចេញចោល ការទុកចោល ឬ ការរក្សាទុកនូវសារធាតុពុលដែលអាចធ្វើឱ្យប៉ះពាល់ដល់គុណភាពទឹក និងអាចបង្កគ្រោះថ្នាក់ដល់មនុស្ស សត្វ និង រុក្ខជាតិ ត្រូវតែសុំអាជ្ញាបណ្ណ័ទឹក ឬ ការអនុញ្ញាត ។

ប្រភេទសារធាតុពុលដែលមានចែងខាងលើ និងស្តង់ដារបច្ចេកទេសនៃការបញ្ចេញទឹកសំណល់នឹងមានកំណត់ដោយអនុក្រឹត្យ ។

រាល់កិច្ចដំណើរការក្នុងមាត្រានេះ ក្រសួងធនធានទឹក និងឧតុនិយមត្រូវពិគ្រោះយោបល់ជាមួយក្រសួងពាក់ព័ន្ធនានា ។

**មាត្រា ២៣.–**

ក្រសួងធនធានទឹក និងឧតុនិយម អាចប្រកាសទុកជាតំបន់អាសន្ន ឬ ជាតំបន់ហាមឃាត់ការប្រើប្រាស់ទឹក ក្នុងករណីដែល :

-ទឹកលើដី ឬ ទឹកក្រោមដីត្រូវបានប៉ះពាល់ផ្នែកបរិមាណ គុណភាព ឬ តុល្យ-ភាពអេកូឡូស៊ី

-ទឹកលើទីជម្រាលដែលកំពុងរងការគំរាមកំហែងដោយសកម្មភាពមនុស្ស ឬ ធម្មជាតិ

-ទឹកដែលបណ្តាលឱ្យប៉ះពាល់ដល់សុខភាពប្រជាពលរដ្ឋ ។

ដែនភូមិសាស្ត្រនៃតំបន់អាសន្ន ឬ តំបន់ហាមឃាត់នោះ ត្រូវកំណត់តាមករណីនីមួយៗ ដោយប្រកាសរបស់ក្រសួងធនធានទឹក និងឧតុនិយម ។

# ជំពូកទី ៧
# ការការពារគ្រោះទឹកជំនន់ និងគ្រោះរាំងស្ងួត

## មាត្រា ២៤.-

ក្នុងការការពារគ្រោះទឹកជំនន់ ក្រសួងធនធានទឹក និងឧតុនិយមដោយសហការជាមួយស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរមូលដ្ឋាន អាចប្រកាសកំណត់តំបន់ទំនាបជាតំបន់ស្រូបយកទឹកជំនន់ ។

នៅក្នុងតំបន់ការពារគ្រោះទឹកជំនន់ ក្រសួងធនធានទឹក និងឧតុនិយមរួមជាមួយស្ថាប័ន និងអាជ្ញាធរមូលដ្ឋានពាក់ព័ន្ធ ត្រូវរៀបចំផែនការស្ដីពីវិធានការទប់ស្កាត់ និងត្រួតពិនិត្យគ្រោះទឹកជំនន់ ដើម្បីធានាសុវត្ថិភាពជីវិតមនុស្ស សត្វ និងទ្រព្យសម្បត្តិ ។

ក្រសួងធនធានទឹក និងឧតុនិយមអាចហាមឃាត់ជាបណ្ដោះអាសន្ននូវសកម្មភាពនានាដែលបង្កការខូចខាតដល់វិធានការការពារគ្រោះទឹកជំនន់ ឬ ដែលរារាំងចរន្តទឹកហូរធម្មជាតិ ។

## មាត្រា ២៥.-

ក្នុងករណីដែលពិនិត្យឃើញថា សំណង់ការងារទឹកទាំងឡាយដែលមិនមានស្ថិរភាពគ្រប់គ្រាន់ ឬ អាចនឹងបង្កឱ្យមានមហន្តរាយប៉ះពាល់ដល់សង្គមជាតិ ក្រសួងធនធានទឹក និងឧតុនិយមត្រូវពិគ្រោះយោបល់ជាមួយក្រសួងពាក់ព័ន្ធ និងអាជ្ញាធរមូលដ្ឋានដើម្បីហាមឃាត់ជាបន្ទាន់ទៅតាមសមត្ថកិច្ចរៀងៗខ្លួន ។

## មាត្រា ២៦.-

នៅពេលមានគ្រោះទឹកជំនន់ និងគ្រោះរាំងស្ងួត ក្រសួងធនធានទឹក និងឧតុនិយមជាសេនាធិការផ្ទាល់ឱ្យរាជរដ្ឋាភិបាលក្នុងការចាត់ចែងការងារ ដោយរួមសហការជាមួយក្រសួងពាក់ព័ន្ធ និងអាជ្ញាធរមូលដ្ឋាន ។

៤

3/18

## ជំពូកទី ៨
## សេវភាព

**មាត្រា ២៧.–**

កម្មសិទ្ធិករ ឬ អ្នកកាន់កាប់ដីផ្នែកខាងលើអាចត្រងទឹកទុក ប្រើប្រាស់ទឹកភ្លៀង និងទឹកហូរកាត់លើដីកម្មសិទ្ធិសម្រាប់គោលបំណងដូចមានចែងក្នុងមាត្រា ១១ នៃច្បាប់នេះ ដោយមិនឱ្យប៉ះពាល់ដល់ផលប្រយោជន៍អ្នកប្រើប្រាស់ទឹកផ្នែកខាងក្រោម ។

កម្មសិទ្ធិករ ឬ អ្នកកាន់កាប់ដីផ្នែកខាងក្រោមអាចទទួលត្រងទឹកទុក និងប្រើប្រាស់បាននូវបរិមាណទឹកធម្មជាតិដែលហូរពីដីផ្នែកខាងលើ ក៏ប៉ុន្តែបុគ្គលទាំងនេះគ្មានសិទ្ធិរាំងចរន្តទឹកដោយសារការសាងសង់ផ្លូវ ទំនប់តូច ធំ ឬ សំណង់ផ្សេងៗទៀតដែលអាចរក្សាទឹកទុកបានឡើយ លើកលែងតែមានការអនុញ្ញាត ។

ការខូចខាតណាមួយបណ្តាលមកពីកម្មសិទ្ធិករ ឬ អ្នកកាន់កាប់ដីដែលបានរំលោភទៅនឹងបទប្បញ្ញត្តិនៃមាត្រានេះ ត្រូវចេញសងនូវការខូចខាតនោះ ។

**មាត្រា ២៨.–**

កម្មសិទ្ធិករ ឬ អ្នកកាន់កាប់ដីកសិកម្ម ត្រូវអនុញ្ញាតឱ្យចរន្តទឹកហូរកាត់លើដីរបស់ខ្លួនតាមលំនាំធម្មជាតិទៅកាន់ដីអ្នកជិតខាង ដើម្បីបំពេញនូវតម្រូវការស្រោចស្រពលើដីកសិកម្ម ឬ តម្រូវការផ្សេងៗទៀត ។

**មាត្រា ២៩.–**

សេវភាពបម្រើប្រយោជន៍សាធារណៈ គឺជាបទប្បញ្ញត្តិពិសេសដែលតម្រូវឱ្យកម្មសិទ្ធិករ ឬ អ្នកកាន់កាប់ដីប្រតិបត្តិតាម ។

អ្នករៀបចំសេវាភាពប្រពន្ធ័នាំទឹកឆ្លងកាត់លើដីអ្នកជិតខាងតាមវិធីនាំទឹកលើដី ឬ ក្រោមដីមិនត្រូវធ្វើឱ្យខូចខាតផលប្រយោជន៍របស់អ្នកដទៃ ឯការបញ្ចេញទឹកចោល ទឹកសំណល់ទឹកភ្លៀង និងការដោះទឹក ក៏ស្ថិតនៅក្នុងក្របខ័ណ្ឌសេវភាពដែរ ។

ក្នុងករណីមានការខូចខាត អ្នកទទួលផលប្រយោជន៍ពីសេវភាពដូចមានចែងក្នុងមាត្រានេះ ត្រូវទទួលខុសត្រូវសងការខូចខាតដល់កម្មសិទ្ធិករ ឬ អ្នកកាន់កាប់ដីដែលជាអ្នករងគ្រោះ ។

**មាត្រា ៣០.-**

ម្ចាស់ដីជិតខាងគ្នាមានសិទ្ធិប្រើប្រាស់សំណង់ដែលមានចែងក្នុងមាត្រា ២៩ នៃច្បាប់នេះ ។

ក្នុងករណីនេះ កម្មសិទ្ធិករត្រូវចូលរួមចំណែកតាមសមាមាត្រនៃការប្រើប្រាស់សំណង់ តម្លៃនៃការសាងសង់ កិច្ចដំណើរការ ការថែទាំសំណង់ និងការចំណាយលើការកែប្រែនានាដែលចាំបាច់ ។

**មាត្រា ៣១.-**

សេវភាពនៃច្បាប់នេះ អស់សុពលភាពស្របតាមបញ្ញត្តិច្បាប់ភូមិបាលស្តីពីសេវភាព ។

**មាត្រា ៣២.-**

រាល់វិវាទដែលពាក់ពន្ធ័ការបង្កើត និងដំណើរការសេវភាពក្នុងការប្រើប្រាស់ទឹកត្រូវសម្រួលដោះស្រាយដោយក្រសួងធនធានទឹក និងឧតុនិយម និងក្រសួងពាក់ព័ន្ធ និងអាជ្ញាធរមូលដ្ឋាន ។

**មាត្រា ៣៣.-**

មន្ត្រីមានសមត្ថកិច្ចនៃក្រសួងធនធានទឹក និងឧតុនិយមដែលធ្វើការតាមដានត្រួតពិនិត្យបច្ចេកទេសពាក់ព័ន្ធនឹងការប្រើប្រាស់ទឹក អាចចូលទៅក្នុងដីកម្មសិទ្ធបានដោយគ្រាន់តែធ្វើសេចក្តីជូនដំណឹងជាលាយល័ក្ខណ៍អក្សរជាមុនទៅដល់កម្មសិទ្ធិករ ឬ អ្នកកាន់កាប់ដី ។

ក្នុងពេលបំពេញបេសកកម្ម មន្ត្រីមានសមត្ថកិច្ចត្រូវមានលិខិតបេសកកម្មរបស់ខ្លួន ។

## ជំពូកទី ៩
## ទន្លេអន្តរជាតិ

**មាត្រា ៣៤.-**

ព្រះរាជាណាចក្រកម្ពុជាមានសិទ្ធិ និងកាតព្វកិច្ចចាត់ចែងចំណែកសមស្រប និងដោយស្មើភាពក្នុងការប្រើប្រាស់ ការអភិវឌ្ឍន៍ និងការគ្រប់គ្រងទន្លេអន្តរជាតិក្នុងទឹកដីរបស់ខ្លួនស្របតាមសិទ្ធិ និងកាតព្វកិច្ចដែលមានចែងក្នុងកិច្ចព្រមព្រៀងអន្តរជាតិ ដែលមានព្រះរាជាណាចក្រកម្ពុជាជាភាគី ។

ក្រសួងធនធានទឹក និងឧតុនិយមយកចិត្តទុកដាក់ឱ្យមានការប្រើប្រាស់ទឹកអាងទន្លេមេគង្គលើគ្រប់វិស័យ ដោយរួមទាំងវិស័យដឹកជញ្ជូនផងឱ្យបានត្រឹមត្រូវ និងមានប្រសិទ្ធភាពស្របតាមគោលការណ៍របស់គណៈកម្មាធិការជាតិទន្លេមេគង្គ ។

## ជំពូកទី ១០
## រង្វាន់លើកទឹកចិត្ត និងទោសប្បញ្ញត្តិ

**មាត្រា ៣៥.-**

រាជរដ្ឋាភិបាលអាចផ្តល់រង្វាន់លើកទឹកចិត្ត ឬ ភាពអនុគ្រោះផ្សេងៗដល់បុគ្គលទាំងឡាយដែលបានចូលរួមក្នុងការសិក្សាស្រាវជ្រាវ ការបង្កើតបច្ចេកវិទ្យាថ្មីៗ ឬ ការដំឡើងឧបករណ៍ទំនើបដែលជួយកាត់បន្ថយកាកសំណល់ និងជួយបង្កើនគុណភាពទឹកដើម្បីឱ្យការប្រើប្រាស់ទឹកមានប្រសិទ្ធភាពខ្ពស់ ។

លក្ខណៈវិនិច្ឆ័យ និងបែបបទសម្រាប់ការផ្តល់រង្វាន់លើកទឹកចិត្ត ឬ ភាពអនុគ្រោះផ្សេងៗត្រូវធ្វើឡើងដោយប្រកាសរបស់ក្រសួងធនធានទឹក និងឧតុនិយម ។

**មាត្រា ៣៦.-**

បទល្មើសនឹងបញ្ញត្តិនៃច្បាប់នេះ ត្រូវទទួលទណ្ឌកម្មដូចតទៅ :

១-ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពីពីររយពាន់ (២០០.០០០)រៀល ដល់ពីរលាន (២.០០០.០០០) រៀល ចំពោះបុគ្គលណាដែល :

-រំលោភលើលក្ខខណ្ឌនានាដែលមានកំណត់ក្នុងអាជ្ញាប័ណ្ណទឹក ។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

6/18

-រារាំងដោយគ្មានមូលហេតុត្រឹមត្រូវ មិនឱ្យមន្ត្រីមានសមត្ថកិច្ចបំពេញនូវតួនាទីរបស់ខ្លួន ។

-សង់សំណង់ជារាសាស្ត្រដោយគ្មានអាជ្ញាប័ណ្ណទឹក ។

២-ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពីពីរលាន (២.០០០.០០០)រៀល ដល់ប្រាំលាន(៥.០០០.០០០)រៀល និង ឬ ដាក់ពន្ធនាគារពីមួយ(១)ខែ ដល់ប្រាំមួយ(៦)ខែ ចំពោះបុគ្គលណាដែល :

-ប្រើប្រាស់ទឹកដោយគ្មានសុំអាជ្ញាប័ណ្ណទឹក ឬ លិខិតអនុញ្ញាត ក្នុងករណីដែលច្បាប់តម្រូវឱ្យមាន ។

-ជីក ឬ ខួងអណ្តូងយកទឹកក្រោមដីធ្វើអាជីវកម្ម ដោយគ្មានអាជ្ញាប័ណ្ណទឹក ។ ប្រាក់ពិន័យនេះនឹងឡើងទ្វេដង កាលណាការជីក ឬខួងអណ្តូងបណ្តាលឱ្យមានការស្រុត ឬបាក់ដី ។ ជនល្មើសត្រូវទទួលខុសត្រូវចំពោះការខូចខាត ដែលបណ្តាលមកពីការស្រុត ឬបាក់ដីនេះ ។

៣-ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពីប្រាំលាន(៥.០០០.០០០)រៀល ដល់ដប់លាន (១០.០០០.០០០)រៀល និង ឬ ដាក់ពន្ធនាគារពីមួយ(១)ឆ្នាំ ដល់ប្រាំ(៥)ឆ្នាំ ចំពោះបុគ្គលណាដែល :

-លុបបឹងធម្មជាតិ ស្រះ ត្រពាំង និងអាងទឹកដោយគ្មានលិខិតអនុញ្ញាត ។

-បង្ហូរចោលទឹកសំណល់ដែលមានជាតិពុលចូលក្នុងប្រភពទឹកដោយគ្មានអាជ្ញាប័ណ្ណទឹក ។

-ធ្វើសកម្មភាពបំពាននៅក្នុងតំបន់ហាមឃាត់ ។

-បង្កឧបសគ្គ ឬ ធ្វើឱ្យរាំងស្ទះដល់លំហូរធម្មជាតិនៃទន្លេ ស្ទឹង ព្រែក អូរ ប្រឡាយដោយគ្មានការអនុញ្ញាត ។

-ធ្វើអាជីវកម្មខ្សាច់ ដី ថ្ម និងក្រួសពីបាតទន្លេ ស្ទឹង ព្រែក និងច្រាំងដោយគ្មានអាជ្ញាប័ណ្ណទឹក ។

៤-គ្រប់ករណីមិនរាងចាល ត្រូវផ្តន្ទាទោសទ្វេមួយជាពីរ ។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

**មាត្រា ៣៧.-**

បុគ្គលណាដែលបង្កឱ្យមានការខូចខាតដល់សំណង់ការងារទឹកសាធារណៈ នឹងត្រូវទទួលការផ្តន្ទាទោសទៅតាមក្រមព្រហ្មទណ្ឌជាធរមាន ។

**មាត្រា ៣៨.-**

បន្ថែមលើទោសប្បញ្ញត្តិដូចមានចែងក្នុងមាត្រាខាងលើ ជនល្មើសត្រូវរុះរើចេញនូវប្រភេទសំណង់ ដែលខ្លួនបានសាងសង់ និងរៀបចំដួសជុលទីកន្លែងឱ្យបានដូចស្ថានភាពដើមវិញ ហើយឧបករណ៍ គ្រឿងចក្រដែលពាក់ព័ន្ធនឹងបទល្មើស ត្រូវរឹបអូសជាសម្បត្តិរដ្ឋ ។

**មាត្រា ៣៩.-**

មន្ត្រីមានសមត្ថកិច្ចនៃក្រសួងធនធានទឹក និងឧតុនិយមដែលបានសមគំនិតជាមួយជនល្មើស ឬ ជួយសម្រួលក្នុងការប្រព្រឹត្តបទល្មើស ត្រូវទទួលទោសចំពោះមុខច្បាប់ ។

## ជំពូកទី ១១
## អវសានប្បញ្ញត្តិ

**មាត្រា ៤០.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៤១.-**

ច្បាប់នេះ ត្រូវប្រកាសជាការប្រញាប់ ។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ២០០៧

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

ពរក.០៧០៦.២៧៣

**នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ
សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ
នាយករដ្ឋមន្ត្រី
**ហត្ថលេខា**
**ហ៊ុន សែន**

បានជម្រាបជូនសម្តេចនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងធនធានទឹក និង ឧតុនិយម
**ហត្ថលេខា**
**លឹម គានហោ**

លេខ ...៣៦.ល
**ចម្លងចែក**
រាជធានីភ្នំពេញ ថ្ងៃទី ... ខែ ... ឆ្នាំ២០០៧
**អគ្គលេខាធិការរងរាជរដ្ឋាភិបាល**
**... វិចេត**